អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## វេទិកាតំបន់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២

**ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១៖** ផ្នែកគាំពារជនរងគ្រោះ (VSS) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំវេទិកាតំបន់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣៥០នាក់ ក្នុងសំណុំរឿង ០០២ មកពីខេត្តភាគខាងត្បូងនៃប្រទេសកម្ពុជា រួមមាន កែប កំពត តាកែវ ព្រះសីហនុ និងកោះកុង។ វេទិកានេះជាវេទិកាថ្នាក់តំបន់លើកដំបូងក្នុងឆ្នាំ២០១១ ដែលនឹងរៀបចំឡើងនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ នៅភោជនីយដ្ឋាន តាអឿ II ក្រុងកំពត ចាប់ពីម៉ោង ៨:០០ព្រឹក។

វេទិកាថ្នាក់តំបន់មានគោលបំណងលើកកម្ពស់ការចូលរួមរបស់ជនរងគ្រោះក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី និងផ្តល់ឱកាសសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី៖

- ជួបជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីពិភាក្សាអំពីសិទ្ធិរបស់ពួកគេលើកិច្ចដំណើរការនីតិវិធីបណ្តឹងដែលកំពុងដំណើរការនៅអង្គជំនុំជម្រះសាលាដំបូង ក៏ដូចជាប្រមូលគំនិតយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីកម្មវិធីសំណងពាក់ព័ន្ធឈានទៅបង្កើតសំណើដាក់ជូន អ.វ.ត.ក។
- ជួបមន្ត្រីមកពីការិយាល័យផ្សេងៗនៃ អ.វ.ត.ក និងតំណាងសង្គមស៊ីវិល ដើម្បីសិក្សាស្វែងយល់អំពីវឌ្ឍនភាពថ្មីៗរបស់ អ.វ.ត.ក។
- ជួបជាមួយដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០១ ដើម្បីស្វែងយល់អំពីបទពិសោធន៍របស់ពួកគេដើម្បីឲ្យមានការចូលរួមកាន់តែប្រសើរឡើងនៅក្នុងសំណុំរឿង ០០២។

VSS នឹងរៀបចំវេទិកាថ្នាក់តំបន់ចំនួនប្រាំផ្សេងទៀតនៅក្នុងតំបន់ផ្សេងៗគ្នាជាបន្តបន្ទាប់ក្នុងឆ្នាំ២០១១ ដើម្បីអាចឱ្យដើមបណ្តឹងរដ្ឋប្បវេណីជាង ២,០០០នាក់ នៅក្នុងសំណុំរឿង ០០២ បានចូលរួម។

Original EN: 01699238-01699238

ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web:www.eccc.gov.kh

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

**លោក អ៊ឹម សុភា**

អ្នកសម្របសម្រួលកម្មវិធីផ្សព្វផ្សាយ

ផ្នែកគាំពារជនរងគ្រោះ អ.វ.ត.ក

ទូរស័ព្ទ៖ +៨៥៥ (0) ៧៧ ៧៧៧ ៣៦៧

ទូរស័ព្ទ៖ +៨៥៥ (0) ២៣ ២១៩ ៨១៤ លេខតំណភ្ជាប់ ៦៦០២

អ៊ីមែល៖ im.sophea@eccc.gov.kh

Original EN: 01699238-01699238